**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ១៩៨៨ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធចាត់តាំង និងការកំណត់តួនាទីរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

បង្កើត "មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន" ហៅកាត់ថា "ម.ស.ក.ជ" ដែលមានឈ្មោះជាភាសាអង់គ្លេសថា **"Cambodia-Japan Cooperation Center"** និងហៅ

កាត់ថា "CJCC។ មជ្ឈមណ្ឌលនេះ ស្ថិតក្រោមរចនាសម្ព័ន្ធរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញនៃក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ២.-**

មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុនមានបេសកកម្ម បណ្តុះបណ្តាលអភិវឌ្ឍធនធានមនុស្ស តាមរយៈការជំរុញវិស័យសេដ្ឋកិច្ចទីផ្សារ និងបន្តការពង្រឹងពង្រីកការយល់ដឹងគ្នាទៅវិញទៅមករវាងប្រទេសកម្ពុជា និងប្រទេសជប៉ុន។

**មាត្រា ៣.-**

មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន កាន់កាប់ និងប្រើប្រាស់គណនេយ្យតាមប្រព័ន្ធគណនេយ្យសាធារណៈ ដែលត្រូវទទួលបានការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីថវិកាជាតិ និងពីភាគីប្រទេសជប៉ុន ព្រមទាំងមានខ្ទង់គណនេយ្យដោយឡែក។

**មាត្រា ៤.-**

មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន ដឹកនាំដោយនាយកមួយរូប ដែលមានឋានៈនិងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន និងមាននាយករងមួយ ឬ ច្រើនរូបជាជំនួយតាមការចាំបាច់។ ដើម្បីជួយសម្រួលដល់កិច្ចសហប្រតិបត្តិការនានា មជ្ឈមណ្ឌលនេះ អាចមានទីប្រឹក្សាជប៉ុន និងអ្នកជំនាញការខាងភាគីប្រទេសជប៉ុន ជាជំនួយបាន។

**មាត្រា ៥.-**

ចំពោះមុខ មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន មាន ០៣ការិយាល័យគឺ :

- ការិយាល័យអភិវឌ្ឍធនធានមនុស្ស
- ការិយាល័យភាសាជប៉ុន
- ការិយាល័យទំនាក់ទំនងវប្បធម៌

ទៅអនាគត ដោយផ្អែកលើតម្រូវការអភិវឌ្ឍជាក់ស្តែង មជ្ឈមណ្ឌលនេះអាចកែសម្រួលរចនាសម្ព័ន្ធបាន។

**មាត្រា ៦.-**

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន ត្រូវកំណត់ឡើងដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយយោងតាមកំណត់ហេតុប្រជុំ និងកំណត់ត្រានៃកិច្ចពិភាក្សារវាងភ្នាក់ងារ JICA និងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៤។

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងនាយកមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន មានភារកិច្ចដើម្បីអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥

**ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៨*
- *រាជកិច្ច*
- *ឯកសារ – កាលប្បវត្តិ*